# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ..១៧៨.សសរ...

## សេចក្តីសម្រេច

## ស្តីពី

## ការបង្កើតគណ:កម្មការអន្តរក្រសួង ដើម្បីជំរុញដំណើរការសិក្សាគម្រោង ផ្លូវរថភ្លើងធុនស្រាលតភ្ជាប់ពីរាជធានីភ្នំពេញ ទៅព្រលានយន្តហោះថ្មី និងផ្លូវរថភ្លើងក្រោមដីរាជធានីភ្នំពេញ

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០២១/០១៤ ចុះថ្ងៃទី១៥ ខែតុលា ឆ្នាំ២០២១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា
- យោងសេចក្តីសម្រេចលេខ ៦១ សសរ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការកំណត់របៀបរបបការងារ និងការបែងចែកភារកិច្ចរបស់ថ្នាក់ដឹកនាំរាជរដ្ឋាភិបាល
- យោងសេចក្តីជូនដំណឹងលេខ ៨៦៥ សជណ ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០២៣ ស្តីពីការបន្តនិរន្តរភាពសម្រាប់គម្រោងហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូនធំៗជាអាទិភាព ក្រោមក្របខណ្ឌនៃកិច្ចសហប្រតិបត្តិការកម្ពុជា-ចិន
- យោងតាមសំណើរបស់ឯកឧត្តម ស៊ុន ចាន់ថុល ឧបនាយករដ្ឋមន្ត្រី អនុប្រធានទី១ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

### សម្រេច

**ប្រការ១.**_

ត្រូវបានបង្កើតគណៈកម្មការអន្តរក្រសួង ដើម្បីជំរុញដំណើរការសិក្សាគម្រោងផ្លូវរថភ្លើងធុនស្រាលតភ្ជាប់ពីរាជធានីភ្នំពេញទៅព្រលានយន្តហោះថ្មី និងផ្លូវរថភ្លើងក្រោមដីរាជធានីភ្នំពេញ ដែលមានសមាសភាពដូចខាងក្រោម÷

| | | | | |
|---|---|---|---|---|
| ១ - | ឯកឧត្តម | **ស៊ុន ចាន់ថុល** | ឧបនាយករដ្ឋមន្ត្រី អនុប្រធានទី១ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | ប្រធាន |
| ២ - | ឯកឧត្តម | **ប៉េង ពោធិ៍នា** | រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន | អនុប្រធានអចិន្ត្រៃយ៍ |
| ៣ - | ឯកឧត្តម | **រស់ សីលវ៉ា** | រដ្ឋលេខាធិការ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | អនុប្រធាន |
| ៤ - | ឯកឧត្តម | **លឹម ពុទ្ធិជាតិ** | អនុរដ្ឋលេខាធិការ ទីស្តីការគណៈរដ្ឋមន្ត្រី | អនុប្រធាន |
| ៥ - | ឯកឧត្តម | **ជា ធុរិទ្ធិ** | អគ្គលេខាធិការគណៈកម្មាធិការវិនិយោគកម្ពុជា | សមាជិក |
| ៦ - | ឯកឧត្តម | **គង់ ចិមាន** | អគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | សមាជិក |
| ៧ - | លោកជំទាវ | **កុយ សុជានី** | រដ្ឋលេខាធិការប្រចាំការ ក្រសួងសាធារណការ និងដឹកជញ្ជូន | សមាជិកា |

៨ - ឯកឧត្តម **ផាន់ ចាន់ធុល** រដ្ឋលេខាធិការ ក្រសួងមហាផ្ទៃ សមាជិក

៩ - ឯកឧត្តម **ជូប សុតក្តិ** អគ្គលេខាធិការរងនៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា សមាជិក

១០ - ឯកឧត្តម **ឡាច ហ៊ាន់** រដ្ឋលេខាធិការ ក្រសួងសាធារណការ និងដឹកជញ្ជូន សមាជិក

១១ - ឯកឧត្តម **ថេង ច័ន្ទសង្វារ** រដ្ឋលេខាធិការ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ សមាជិក

១២ - ឯកឧត្តម **ឈឿន ប៊ុណ្ណារ័ត្ន** រដ្ឋលេខាធិការ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ សមាជិក

១៣ - ឯកឧត្តម **លុច្ស រចនា** រដ្ឋលេខាធិការ និងជានាយកខុទ្ទកាល័យ ក្រសួងសាធារណការ និងដឹកជញ្ជូន សមាជិក

១៤ - ឯកឧត្តម **ឆា ជុប** រដ្ឋលេខាធិការ ក្រសួងបរិស្ថាន សមាជិក

១៥ - ឯកឧត្តម **តិក សារឹ** រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល សមាជិក

១៦ - ឯកឧត្តម **សំរ៉េង ឪណាម៉ូ** អនុរដ្ឋលេខាធិការ ក្រសួងសាធារណការ និងដឹកជញ្ជូន សមាជិក

១៧ - ឯកឧត្តម **ប៉ែន ធីរុទ្ធ** អនុរដ្ឋលេខាធិការ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សមាជិក

១៨ - ឯកឧត្តម **ស៊ឹម ធីរៈ** អនុរដ្ឋលេខាធិការ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សមាជិក

១៩ - ឯកឧត្តម **សួន តារិទ្ធ** នាយកខុទ្ទកាល័យ ឧបនាយករដ្ឋមន្ត្រី ស៊ុន ចាន់ថុល សមាជិក

២០ - ឯកឧត្តម **សរ សិនិរ៉ា** អគ្គលេខាធិការរង គណៈកម្មាធិការវិនិយោគកម្ពុជា សមាជិក

២១ - ឯកឧត្តម **សួន សុផល** អគ្គលេខាធិការរង គណៈកម្មាធិការវិនិយោគកម្ពុជា សមាជិក

២២ - ឯកឧត្តម **អ៊ឹម សិទ្ធីរ៉ា** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកអគ្គនាយក នៃអគ្គនាយកដ្ឋានផលប៉ះពាល់ដោយសារគម្រោងអភិវឌ្ឍន៍ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សមាជិក

២៣ - ឯកឧត្តម **ឱម ម៉ាក់ណារិទ្ធ** អគ្គនាយក អគ្គនាយកដ្ឋានភាពជាដៃគូរវាងរដ្ឋ និងឯកជន ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សមាជិក

២៤ - ឯកឧត្តម **កែន រដ្ឋា** អគ្គនាយក អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ ក្រសួងសាធារណការ និងដឹកជញ្ជូន សមាជិក

២៥ - ឯកឧត្តម **ឈួន ច័ន់** អគ្គនាយក អគ្គនាយកដ្ឋានដឹកជញ្ជូនផ្លូវគោក ក្រសួងសាធារណការ និងដឹកជញ្ជូន សមាជិក

២៦ - ឯកឧត្តម **ឃួង ស្រេង** អភិបាលនៃគណៈអភិបាលរាជធានីភ្នំពេញ សមាជិក

២៧ - ឯកឧត្តម **គង់ សោភ័ណ្ឌ** អភិបាលនៃគណៈអភិបាលខេត្តកណ្តាល សមាជិក

២៨ - លោក **វ៉ាយ រុំ** អនុប្រធាននាយកដ្ឋានផ្លូវដែក ក្រសួងសាធារណការ និងដឹកជញ្ជូន សមាជិក

២៩ - លោក **វ៉ាន់ សីហៈគីរី** នាយកផែនការយុទ្ធសាស្ត្រ និងគម្រោងការ ក្រសួងរ៉ែ និងថាមពល សមាជិក

៣០ - លោក **ទ្រី ដារាលុច** នាយករងខុទ្ទកាល័យ ឧបនាយករដ្ឋមន្ត្រី ស៊ុន ចាន់ថុល សមាជិក

៣១ - លោក **ហេង តុលា** ជំនួយការខុទ្ទកាល័យ ឧបនាយករដ្ឋមន្ត្រី ស៊ុន ចាន់ថុល សមាជិក

៣២ - តំណាងអគ្គនាយកដ្ឋានពន្ធដារ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សមាជិក

៣៣ - តំណាងអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សមាជិក

៣៤ - តំណាងអគ្គនាយកដ្ឋានថវិកា ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សមាជិក

៣៥ - តំណាងអគ្គនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងគ្រប់គ្រងបំណុល ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សមាជិក។

**ប្រការ២._**

គណៈកម្មការអន្តរក្រសួងនេះមានភារកិច្ចដូចតទៅ÷

- ពិនិត្យ ផ្ដល់យោបល់អំពីនីតិវិធី ក្របខណ្ឌគតិយុត្ត និងទម្រង់នៃការវិនិយោគលើគម្រោងផ្លូវរថភ្លើងធុនស្រាល តភ្ជាប់ពីរាជធានីភ្នំពេញ ទៅព្រលានយន្តហោះថ្មី និងផ្លូវរថភ្លើងក្រោមដីរាជធានីភ្នំពេញ
- ជំរុញគម្រោងហេដ្ឋារចនាសម្ព័ន្ធផ្លូវរថភ្លើងធុនស្រាលនេះ ឱ្យបានសម្រេចជាស្ថាពរ ដើម្បីរួមចំណែកពន្លឿនការអភិវឌ្ឍវិស័យដឹកជញ្ជូនអ្នកដំណើរចេញ ចូលមកកាន់ ទីក្រុង និង កាត់បន្ថយចរាចរណ៍ ដែលកំពុងតែមមាញឹកខ្លាំង នៅក្នុងទីក្រុងភ្នំពេញ
- ធ្វើរបាយការណ៍ស្ដីពីលទ្ធផលការងារជូនប្រមុខរាជរដ្ឋាភិបាល។

**ប្រការ៣._**

គណៈកម្មការអន្តរក្រសួងនេះ អាចបង្កើតអនុគណៈកម្មការមួយចំនួនតាមការចាំបាច់។

**ប្រការ៤._**

អនុប្រធាន និងសមាជិកនៃគណៈកម្មការអន្តរក្រសួងនេះ ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធានគណៈកម្មការអន្តរក្រសួង។ ករណីប្រធានអវត្តមាន ត្រូវប្រគល់ជូនអនុប្រធាន១រូប ដឹកនាំប្រជុំជំនួស។ ប្រធានគណៈកម្មការអន្តរក្រសួងមានសិទ្ធិអញ្ជើញតំណាងពីក្រសួង-ស្ថាប័ននានា ឱ្យចូលរួមដើម្បីពិនិត្យ និងផ្ដល់យោបល់ តាមការចាំបាច់។

គណៈកម្មការអន្តរក្រសួងនេះ មានទីតាំងនៅក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា និងមានសិទ្ធិប្រើប្រាស់ត្រារបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា។

**ប្រការ៥._**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្ដីសម្រេចនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៦._**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អនុប្រធានទី១ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនត្រូវទទួលបន្ទុកអនុវត្តសេចក្ដីសម្រេចនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ សុក្រ ៥កើត ខែ កត្ដិក ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ២០២៣

**នាយករដ្ឋមន្ត្រី**

**សម្ដេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

កន្លែងទទួល:
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្ដេចមហាបវរធិបតី នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
  ដូចប្រការ៦
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ